Vol. 2, No. 4 / ខែធ្នូ ឆ្នាំ2025

EQUITY ENGAGEMENT & PARTNERSHIPS
LONG BEACH UNIFIED SCHOOL DISTRICT

# ព្រឹត្តិបត្រព័ត៌មាន

@ lbusdengage    lbschools.net/engage    LONG BEACH UNIFIED • SCHOOL • DISTRICT Excellence and Equity



## ព្រឹត្តិការណ៍ដ៏សំខាន់មួយ

### EONA

EONA (កម្មវិធីអប់រំសំរាប់ជនជាតិអាមេរិកាំងដើម និងជនជាតិ អាឡាស្កា) បានបើកការប្រជុំលើកដំបូងប្រចាំឆ្នាំ និងមានវគ្គវប្បធម៌មួយ ដែលបានលើកបង្ហាញរបៀបធ្វើកន្ត្រកជាប្រពៃណីរបស់ Tongva ក្រោមការដឹកនាំដោយ Mitzla Aguilera ដែលជាអ្នកគ្រប់គ្រងវត្ថុវប្បធម៌ ពីមហាវិទ្យាល័យ Cal State University, Long Beach និងម្តាយរបស់នាង។ ការប្រជុំ EONA ធ្វើឡើងរាល់ខែ។ ដើម្បីទទួលបាននូវព័ត៌មានបន្ថែម សូមចុចយកនៅទីនេះ (click here)។

## នៅក្នុងការចុះផ្សាយនេះ


- **C.A.F.E. – មានចំណុចសំខាន់ៗនៅក្នុងការប្រជុំលើកទីមួយរបស់យើង ដែលត្រូវបានដកស្រង់ពីបទបង្ហាញរបស់ LBCC និងក្រុមរក្សាសុវត្ថិភាពប្រចាំមន្ទីរអប់រំ LBUSD (ទំព័រ 3)**
- **ការធ្វើសកម្មភាពរបស់ក្រុមការងារ EEP នៅតាមសាលារៀន ជាមួយក្រុមគ្រួសាររបស់មន្ទីរអប់រំ LBUSD (ទំព័រ 3)**
- **វិដេអូអំពីព័ត៌មានថ្មីៗទាក់ទងនឹងថវិកា (ទំព័រ 4)**
- **កាលវិភាគសំរាប់ការប្រជុំក្រុមមាតាបិតា (ទំព័រ 2 & 5)**
- **ពិព័រណ៍ចូលទស្សនានៅសាលាបំពេញវិជ្ជាសំរាប់មនុស្សពេញវ័យនៅឡុងបិច (ទំព័រ 4)**
- **ធនធានសំរាប់ពេលឈប់សំរាករដូវរងា (ទំព័រ 4)**




## រួមគ្នា យើងកំពុងតែកសាងអនាគតកាន់តែប្រសើរ - នៅក្នុង និងជាមួយសហគមន៍របស់យើង!

នៅពេលដែលយើងបិទបញ្ចប់ឆ្នាំប្រតិទិន គឺយើងខ្ញុំមានមោទនភាពក្នុងការបន្តភាពលូតលាស់ជាដៃគូជាមួយក្រុមគ្រួសារទូទាំងមន្ទីរអប់រំ។ ខែនេះបង្ហាញអំពីការបង្កើតនូវវគ្គប្រជុំថ្មីមួយរបស់យើង ហៅ C.A.F.E. (ទំនាក់ទំនងជាមួយសហគមន៍ និងក្រុមគ្រួសារ) — ជាឱកាសត្រូវបានរៀបចំឡើង ដើម្បីប្រមូលផ្តុំជាប្រធានបទដែលក្រុមគ្រួសារតែងតែស្នើចង់បានក្នុងការពិភាក្សាគ្នា ស្របដោយភាពកក់ក្តៅ និងភាពរាក់ទាក់។ វគ្គប្រជុំទាំងអស់នេះធ្វើការផ្តោតមកលើការបង្កើនសមត្ថភាពរបស់មាតាបិតា និងការប្រគល់អំណាចមកកាន់ក្រុមគ្រួសារជាមធ្យោបាយ និងចំណេះក្នុងការគាំទ្រដំណើរការសិក្សានៃសិស្សរបស់ពួកគេ។

ក្រុមការងាររបស់យើងមានការជាប់រវល់ខ្លាំងជាមួយដំណើរការជ្រើសរើសវិទ្យាល័យ (High School Choice) ដែលពួកយើងធ្វើការជាមួយក្រុមគ្រួសារនៃសិស្សថ្នាក់ ទី8 និងសាលារៀនផ្សេងៗ ដើម្បីបញ្ជាក់ថាសិស្ស និងអ្នកមើលថែ ពិតជាបានទទួលនូវការគាំទ្រ និងព័ត៌មានច្បាស់មែន ខណៈពេលដែលពួកគេធ្វើគំរោងសំរាប់វគ្គសិក្សាជាបន្ត។ ក្រុមការងារ Parent University នៅតែបន្តការបើកផ្តល់សិក្ខាសាលា ទៀងទាត់តាមពេលវេលាល្ងាច ដែលត្រូវតាមសេចក្តីត្រូវការរបស់មាតាបិតា។

នៅខែធ្នូ គឺយើងខ្ញុំបើកផ្តល់សិក្ខាសាលាមួយស្តីអំពី "ការណែនាំបង្ហាញកម្មវិធីអប់រំពិសេស" ដែលជាវគ្គមួយត្រូវបានរៀបចំឡើងដើម្បីជួយក្រុមគ្រួសារយល់ដឹងកាន់តែច្បាស់អំពីដំណើរការចាត់ចែងក្នុងកម្មវិធីអប់រំពិសេស និងមធ្យោបាយគាំទ្រយ៉ាងកក់ក្តៅមកលើសេចក្តីត្រូវការផ្នែកសិក្សានៃសិស្សរបស់ពួកគេ។ យើងខ្ញុំដឹងគុណណាស់ចំពោះទំនុកចិត្តដែលអ្នកបានផ្តល់មកកាន់យើងខ្ញុំ និងការបន្តភាពជាដៃគូរបស់អ្នក។

Dr. Lucy Salazar



# ក្រុមសំរាប់ការចូលរួមរបស់មាតាបិតា



## ក្រុមមាតាបិតានានា

ក្រៅតែពីកម្មវិធី CAFE គឺក្រុមគ្រួសារអាចចូលរួមក្នុងក្រុមមាតាបិតានានាបាន ដែលបង្កើតចេញពីជំនាញឯកទេស និងបទពិសោធន៍ ដែលពួកគេនាំមកតាមខ្លួន ដោយក្នុងពេលទន្ទឹមគ្នានោះដែរ គឺផ្តល់នូវឱកាសដ៏មានអត្ថន័យសំរាប់ការដឹកនាំ ការរីកចំរើន និងការរៀនសូត្រផងដែរ។ ក្រុមមាតាបិតាទាំងនេះនាំមាតាបិតាឱ្យជួបជុំគ្នា ដើម្បីរៀនសូត្រអំពីគំនិតផ្តួចផ្តើមរបស់មន្ទីរជាច្រើន ចែករំលែកមតិយោបល់ និងសហការគ្នា អំពីមធ្យោបាយក្នុងការជួយជ្រោមជ្រែងដល់សិស្សទាំងអស់។ តាមរយៈការចូលរួមក្នុងក្រុមនេះ គឺមាតាបិតាមិនត្រឹមតែពង្រឹងនូវជំនាញក្នុងការដឹកនាំរបស់ពួកគេតែប៉ុណ្ណោះទេ ប៉ុន្តែក៏ជួយបង្កើតនូវអនាគតរបស់សាលា និងសហគមន៍នានារបស់យើងផងដែរ។





### DISTRICT COMMUNITY ADVISORY COMMITTEE
LONG BEACH UNIFIED SCHOOL DISTRICT

គណៈកម្មការប្រឹក្សាសហគមន៍ប្រចាំមន្ទីរអប់រំ (DCAC) គឺមានសមាភាគជាតំណាងមាតាបិតាមកពីសាលា LBUSD ទាំងឡាយ ដែលឧបត្ថម្ភដោយមូលនិធិសហព័ន្ធ Title 1។
មាតាបិតា ត្រូវបានផ្តល់ឱកាសឱ្យចូលរួមពាក់ព័ន្ធ និងទទួលដំណឹងអំពីការសិក្សារបស់កូនពួកគេ។ មាតាបិតា ត្រូវបានលើកទឹកចិត្តឱ្យចែករំលែកព័ត៌មានប្រជុំ ជាមួយមាតាបិតាផ្សេងៗទៀតនៅសាលារបស់ពួកគេ។ **ការប្រជុំលើកក្រោយ៖ ថ្ងៃព្រហស្បតិ៍ ទី18 ខែធ្នូ នៅវិទ្យាល័យ Browning – ម៉ោង 5:30 ល្ងាច**



### SANKOFA PARENT VILLAGE
LONG BEACH UNIFIED SCHOOL DISTRICT

ភូមិមាតាបិតាសាំងកូហ្វា (SPV) ជាសហគមន៍មើលថែនិងជួយផ្គត់ផ្គង់សម្រាប់មាតាបិតា និងអ្នកមើលថែរបស់កុមារអាមេរិកខ្មៅ។ មន្ទីរអប់រំ LBUSD ប្តេជ្ញាផ្តោតចិត្តទុកដាក់លើតម្រូវការពិសេសរបស់សមាជិកសហគមន៍របស់យើង និងចូលរួមតាមរបៀបដែលលើកកំពស់ដល់អត្តសញ្ញាណវប្បធម៌របស់ពួកគេ។
ការប្រុជំលើកក្រោយ៖ **ថ្ងៃច័ន្ទ ទី12 ខែមករា នៅមជ្ឈមណ្ឌលធនធានគ្រូបង្រៀន – 5:30 ល្ងាច**



### DISTRICT ENGLISH LEARNER ADVISORY COMMITTEE
LONG BEACH UNIFIED SCHOOL DISTRICT

គណៈកម្មការប្រឹក្សាសិស្សរៀនភាសាអង់គ្លេសប្រចាំមន្ទីរអប់រំ (DELAC) ជាវិធីសំរាប់ឱ្យមាតាបិតា អាចចូលរួមចំណែកក្នុងការអប់រំរបស់កូនពួកគេ នៅកំរិតមន្ទីរអប់រំបាន។ តំណាងរបស់ DELAC មាតាបិតា ថ្នាក់ដឹកនាំមន្ទីរអប់រំ និងសមាជិកសហគមន៍ចូលរួមក្នុងការប្រជុំទាំងនេះ ជារៀងរាល់ខែ។
**ការប្រជុំលើកក្រោយ៖**
**ថ្ងៃអង្គារ ទី6 ខែមករា 2026 នៅវិទ្យាល័យ Browning – ម៉ោង 9:30 ព្រឹក**



### EDUCATIONAL OPPORTUNITIES for NATIVE AMERICANS and NATIVE ALASKANS
LONG BEACH UNIFIED SCHOOL DISTRICT

កម្មវិធីរបស់យើង ត្រូវបានរចនាបង្កើតឡើង ដើម្បីធានាថា សិស្សជនជាតិដើមអាមេរិក (AI)/ និងជនជាតិដើមអាឡាស្កា (AN) នៅក្នុងមន្ទីរអប់រំឡុងប៊ីចមានឱកាសស្មើភាពគ្នា ក្នុងការទទួលបានការអប់រំ។ មាតាបិតា អាណាព្យាល បុគ្គលិកមន្ទីរ និងដៃគូនៅតាមសហគមន៍ ចូលរួមក្នុងការរៀបចំផែនការកម្មវិធីសិក្សា និងព្រឹត្តិការណ៍ផ្សេងៗ។ **ការប្រជុំលើកក្រោយ៖ ថ្ងៃអង្គារ ទី20 ខែមករា នៅវិទ្យាល័យ  Browning ក្នុងបន្ទប់ប្រជុំធំ – 5:30 ល្ងាច**

# សិក្ខាលាលាសំរាប់មាតាបិតា
## ដើម្បីរៀនសូត្រ រីកចំរើន និងពង្រឹងសិទ្ធិអំណាច រួមជាមួយគ្នា៖ នៅក្នុង និង ជាមួយ សហគមន៍

## C.A.F.E.
ការចូលរួមសំរាប់សហគមន៍ និង គ្រួសារ

NEW



នៅក្នុងសិក្ខាមាតាបិតាសាលាថ្មីៗរបស់យើងនេះ គឺក្រុមគ្រួសារបានទទួលស្តាប់ព័ត៌មានពីវាគ្មិនពីរនាក់ គឺ Pre Williams ជាតំណាងពីអនុមហាវិទ្យាល័យ Long Beach City College ដែលអ្នកស្រីបានធ្វើការចែករម្លែកអំពីឱកាសដែលសិស្សអនុវិទ្យាល័យ និងសិស្សវិទ្យាល័យអាចចុះឈ្មោះរៀននៅតាមពីរកន្លែងបាន ហើយអ្នកស្រីបានពន្យល់ជូនក្រុមគ្រួសារអំពីមធ្យោបាយដែលសិស្សអាចចាប់ផ្តើមទទួល ក្រេឌិត បានតាំងពីដើមដំបូងមកសំរាប់ត្រៀមទុកចូលរៀននៅមហាវិទ្យាល័យ។





យើងក៏បានទទួលស្វាគមន៍ផងដែរចំពោះលោក Cameron Smith ជានាយកគ្រប់គ្រងសុវត្ថិភាពសាលារៀនប្រចាំមន្ទីរអប់រំ LBUSD ដែលលោកបានលើកបង្ហាញព័ត៌មានសង្ខេបអំពីការប្តេជ្ញាចិត្តរបស់ការិយាល័យសុវត្ថិភាពសាលារៀន ដើម្បីបង្កើតជាបរិយាកាសសិក្សា ស្របដោយសុវត្ថិភាព ការគាំទ្រ និងការបញ្ចុះបញ្ចូលគ្នាមកលើសិស្សទាំងអស់—ទោះបីពួកគេមានឋានៈជាជនអន្តោប្រវេសន៍ប្រភេទណាក៏ដោយ។ លោកបានពិគ្រោះអំពីចំណុចសំខាន់ៗដែលមាននៅក្នុងគំរោងសុវត្ថិភាពនៃមន្ទីរអប់រំរបស់យើង និងមធ្យោបាយជាច្រើនទៀតដែលក្រុមរក្សាសុវត្ថិភាពធ្វើសហការជាមួយសាលារៀនដើម្បីមើលថែបរិវេណឱ្យនៅតែជាកន្លែងមានសុវត្ថិភាពសំរាប់សិស្សធ្វើការផ្តោតមកលើការសិក្សា។









**សូមចូលរួមជាមួយយើងខ្ញុំនៅ ថ្ងៃសុក្រ ទី19 ខែធ្នូ ឆ្នាំ2025 នៅវិទ្យាល័យ Browning ម៉ោង 9:30 ព្រឹក**

## PARENT UNIVERSITY
LONG BEACH UNIFIED SCHOOL DISTRICT



មានវគ្គសិក្ខាសាលាជាបន្តបន្ទាប់ ដែលបានរចនាបង្កើតឡើង ដើម្បីជួយ និងផ្តល់សិទ្ធិអំណាចដល់ក្រុមគ្រួសារ ឱ្យក្លាយជាដៃគូសហការដ៏ពេញលេញ នៅក្នុងការអប់រំរបស់កូនពួកគេ។ មាតាបិតា និងអ្នកមើលថែ របស់ LBUSD ត្រូវបានស្វាគមន៍ឱ្យចូលរួម។ មានផ្តល់ជូនមធ្យោបាយយានជំនិះ ការមើលថែកុមារ ការជួយធ្វើលំហាត់កិច្ចការផ្ទះ ហើយនិងសេវាបកប្រែភាសា។





**សូមចូលរួមជាមួយយើងខ្ញុំនៅ ថ្ងៃព្រហស្បតិ៍ ទី8 ខែមករា ឆ្នាំ2026 នៅវិទ្យាល័យ ម៉ោង 5:30 ល្ងាច**

## DISTRICT COMMUNITY ADVISORY COMMITTEE
LONG BEACH UNIFIED SCHOOL DISTRICT

**សូមអរគុណចំពោះអ្នកទាំងអស់គ្នាដែលបានចូលរួមក្នុងការប្រជុំ DCAC របស់យើងនៅថ្ងៃទី19 ខែវិច្ឆិកា តាមរយៈ Zoom។ អគ្គនាយក Dr. Jill Baker និងបុគ្គលិក LBUSD ដែលមានលោក Steve Rockenbach (ទំនាក់ទំនងបុគ្គលិក) អ្នកស្រី Nicole Lopez (នាយកសាលារៀនសំរាប់មនុស្សពេញវ័យ ឡុងប៊ីច) និងអ្នកស្រី Margaret Lam (ហិរញ្ញវត្ថុ) បានធ្វើការចែករម្លែកព័ត៌មានថ្មីៗអំពីថវិការបស់មន្ទីរអប់រំ ក្រុមការងារសុជីវធម៌ និងកម្មវិធីដែលបើកទទួលនៅតាមសាលារៀនសំរាប់មនុស្សពេញវ័យ ឡុងប៊ីច។**

**បើអ្នកមិនទាន់បានចូលរួមជាមួយ DCAC នៅឡើយ គឺយើងខ្ញុំសូមអញ្ជើញអ្នកតំណាងមាតាបិតា/អាណាព្យាបាល ចូលរួមផ្ទាល់ក្នុងការប្រជុំលើកក្រោយដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី18 ខែធ្នូ នៅវិទ្យាល័យ Browning ម៉ោង 5:30–6:30 ល្ងាច។ យើងខ្ញុំសង្ឃឹមថា អ្នកនឹងចូលរួម!**













**បុគ្គលិក EEP បានជួយក្រុមគ្រួសារនៅតាមសាលារៀនអំពីការដាក់ពាក្យជ្រើសរើសវិទ្យាល័យ នៅអនុវិទ្យាល័យ Stephens និងតាមរយៈធ្វើបទបង្ហាញជាបន្តបន្ទាប់ ដោយក្រុមការងារ Parent University នៅវិទ្យាល័យ Poly។**




ថ្ងៃសុក្រ ទី12 ខែធ្នូ ឆ្នាំ2025

**171 W. Bort St., Long Beach, CA 90805**

10 ព្រឹក

សូមចូលរួមជាមួយយើងខ្ញុំនៅក្នុងទីតាំងថ្មីប៉ែក ឡុងប៊ីច ខាងជើង! អ្នកនឹងរៀនអំពីកម្មវិធីរបស់យើង ជួបបុគ្គលិក និងសិស្សរបស់យើង រួមទាំងនឹងបានទទួលនូវបទពិសោធន៍នៅក្នុងបរិវេណថ្មីរបស់យើង!

សូមចុចលើរូបភាព ដើម្បីទទួលបាននូវព័ត៌មានបន្ថែម។




## ធនធានសំរាប់គ្រួសារនៅពេលឈប់សំរាករដូវរងា

នៅពេលឈប់សំរាករដូវរងាជិតចូលមកដល់ គឺយើងខ្ញុំដឹងថា មានក្រុមគ្រួសារប្រហែលជារង់ចាំជំនួយ ការបំប៉ន និងមធ្យោបាយរីករាយផ្សេងៗក្នុងការចំណាយពេលជុំគ្នា។ ដើម្បីជួយបាន គឺយើងខ្ញុំបានប្រមូលផ្តុំនូវបញ្ជីរាយបង្ហាញអំពីធនធាននៅតាមសហគមន៍ដែលនឹងមានចែកផ្តល់ក្នុងរយៈពេលសំរាក។ មានតាំងពីកម្មវិធីជំនួយអាហារ និងការដាក់ផ្ញើសិស្ស រហូតដល់ការចែកផ្តល់គ្រឿងលេងកំសាន្ត។ មានអ្វីៗសព្វយ៉ាងសំរាប់អ្នកទាំងអស់គ្នា។ សូមចុចនៅតាមបណ្តាញ។



**ការផ្ញើសិស្ស**

**ការចែកអាហារ**





**គ្រឿងលេង**



## ដៃគូក្នុងការអប់រំ នៅអនុវិទ្យាល័យ Stanford

អ្នកសំរបសំរួលកម្មវិធីមាតាបិតា គឺអ្នកស្រី Amie Chikami នៅអនុវិទ្យាល័យ Stanford បានបើកសិក្ខាសាលាមួយ ហៅ ដៃគូក្នុងការអប់រំ សំរាប់មាតាបិតាមកពីអនុវិទ្យាល័យ Stanford និង Marshall ចូលរួម។

## ការដាក់ពាក្យជ្រើសរើសវិទ្យាល័យ

### ថ្នាក់សិក្សាអនាគតកាលនៃឆ្នាំ2030!

**យើងខ្ញុំមានសេចក្តីរីករាយក្នុងការគាំទ្រសិស្សថ្នាក់ទី 8 និងគ្រួសារ ខណៈពេលដែលអ្នកត្រៀមចូលរៀននៅតាមវិទ្យាល័យក្នុងរដូវស្លឹកឈើធ្លាក់ នៃឆ្នាំ2026។**

- **ការដាក់ពាក្យជ្រើសរើសវិទ្យាល័យ គឺបើកទទួលនៅថ្ងៃទី10 ខែវិច្ឆិកា ឆ្នាំ2025 តាមការប្រើក្នុងប្រព័ន្ធ ParentVUE។**
- **សិស្សថ្មី ឬ សិស្សរស់នៅ ឡុងប៊ីច ដែលត្រឡប់មកមន្ទីរអប់រំ LBUSD វិញ គឺអាចផ្ញើបញ្ជូនឯកសារតាម អនឡាញ បាន ចាប់ផ្តើមនៅថ្ងៃទី13 ខែតុលា ឆ្នាំ2025 ដើម្បីទទួលបាននូវសិទ្ធិជំរើសវិទ្យាល័យ។**

**ចុចនៅទីនេះ ដើម្បីទទួលបាននូវធនធានផ្សេងៗ ដែលជាការណែនាំសំរាប់អ្នកចាត់ចែងធ្វើតាមវិធានការជាបន្តបន្ទាប់។**

**ការិយាល័យជំរើសវិទ្យាល័យ**

**តាមទូរស័ព្ទ៖ (562) 997-8306 ឬ**

**HSMSChoicehelp@lbschools.net**

**ចូលរួមជាមួយយើងខ្ញុំក្នុងទស្សកិច្ចវិទ្យាល័យ**


EQUITY ENGAGEMENT & PARTNERSHIPS — LONG BEACH UNIFIED SCHOOL DISTRICT

2025-2026

High School Choice Site Visits

LEARN ABOUT PATHWAYS AND PROGRAMS AT EACH OF THE LBUSD HIGH SCHOOLS

| | |
| --- | --- |
| Thursday, November 13 5:00pm - 8:00pm | Renaissance High School for the Arts 235 E. 8th St. LB, CA 90813 |
| Saturday, November 15 10:00am - 12:00pm | California Academy of Math and Science (CAMS) 1000 E. Victoria St. Carson, CA 90747 (CSUDH Campus) |
| Monday, November 17 5:00pm - 8:00pm | Wilson High School 4400 E. 10th St. LB, CA 90804 |
| Tuesday, November 18 5:30pm - 7:30pm | Browning Early College High School 2180 Obispo Ave. LB, CA 90804 |
| Thursday, November 20 5:00pm - 8:00pm | Jordan High School 6500 Atlantic Ave. LB, CA 90805 |
| Tuesday, December 2 5:00pm - 7:00pm | Sato Academy of Mathematics and Science 1100 Iroquois Ave. LB, CA 90815 |
| Wednesday, December 3 5:00pm - 7:00pm | Cabrillo High School 2001 Santa Fe. Ave. LB, CA 90810 |
| Thursday, December 4 5:00pm - 8:00pm | Polytechnic High School 1600 Atlantic Ave. LB, CA 90813 |
| Monday, December 8 5:30pm - 7:30pm | McBride High School 7025 E. Parkcrest St. LB, CA 90808 |
| Tuesday, December 9 5:00pm - 8:00pm | Lakewood High School 4400 Briercrest Ave. LB, CA 90713 |
| Wednesday, December 10 5:00pm - 8:00pm | Millikan High School 2800 Snowden Ave. LB, CA 90815 |

HS APPLICATION WINDOW: NOVEMBER 10 - DECEMBER 12, 2025

562-997-8306 | HSMSCHOICEHELP@LBSCHOOLS.NET

LBSCHOOLS.NET/ENGAGE




**សូមជូនពរដល់សហគមន៍ LBUSD របស់យើងឱ្យបានទទួលតែសេចក្តីសុខ និងសេចក្តីរីករាយនៅក្នុងពេលឈប់សំរាករដូវរងា និងនៅក្នុងឆ្នាំថ្មី!**

## ព័ត៌មានថ្មីៗក្នុងខែធ្នូអំពីថវិកា

មានសកម្មភាពដ៏សំខាន់ខ្លះៗ ត្រូវបានលើកបង្ហាញក្នុងមន្ទីរអប់រំ LBUSD ស្តីអំពីថវិកា។ ដំណើរការឆ្ពោះទៅកាន់ស្ថិរភាពសារពើពន្ធ ដែលកំពុងស្ថិតនៅក្រោមការស្រកចុះនៃចំនួនសិស្សចុះឈ្មោះ ការបន្ថយប្រាក់ចំណូល និងការសន្ទត់ចំពោះការបាត់បង់ធនធានពីសហព័ន្ធ គឺតំរូវឱ្យមានការប្រើមធ្យោបាយ ទាំងគោលដៅខ្លី និងគោលដៅវែងឆ្ងាយ ដើម្បីធ្វើឱ្យមន្ទីរអប់រំរក្សាទុកនូវការយកចិត្តទុកដាក់មកលើសមិទ្ធិផលសិក្សា។ ដោយកាន់ភ្ជាប់ជាមួយទស្សនៈវិស័យ2035 និងគោលដៅ និងវិធានការទ្រទ្រង់របស់ក្រុមប្រឹក្សាភិបាលអប់រំ គឺបុគ្គលិកនៅតែបន្តជួបបញ្ហាប្រឈមនឹងការធ្វើសេចក្តីសំរេចមកលើអាទិភាព និងស្ថិរភាពពាក់ព័ន្ធថវិការបស់មន្ទីរអប់រំ។ បញ្ហាស្មុគ្រស្មាញទាំងអស់នេះ នឹងមានបន្តរហូតដល់ពេល យ៉ាងតិចណាស់ ប្រាំឆ្នាំទៅមុខ។

lbschools.net/budget.




Click on the image to watch a video

## ព័ត៌មានចុះផ្សាយដោយក្រុមប្រឹក្សាភិបាលអប់រំ LBUSD ក្នុងខែវិច្ឆិការ




Click on the image to watch a video

# ព្រឹត្តិការណ៍ជាបន្តបន្ទាប់ និង ឱកាសធ្វើទំនាក់ទំនង

សូមឆែកមើលនៅតាមចំណែកនេះរាល់ខែអំពីសិក្ខាសាលា ការប្រជុំមាតាបិតា និងព្រឹត្តិការណ៍ផ្សេងៗ ដែលនឹងរៀបចំផ្តល់ជូនជាបន្តបន្ទាប់។ សូមកុំភ្លេចអំពីឱកាសរៀនរាក់ទាក់ស្គាល់គ្នា ទទួលការសិក្សា និងធ្វើទំនាក់ទំនងជាមួយសហគមន៍សាលារៀនរបស់យើង។

## ខែធ្នូ

| S | M | T | W | TH | F | S |
|---|---|---|---|---|---|---|
| | 1 | 2 ប្រជុំ DELAC នៅវិទ្យាល័យ Browning ម៉ោង 9:30 ព្រឹក | ប្រជុំ CAC នៅវិទ្យាល័យ Browning ម៉ោង 6:00 ល្ងាច | 4 | 5 | 6 កម្មវិធី Sankofa ថ្ងៃសៅរ៍ |
| 7 | 8 ប្រជុំ Sankofa សំរាប់មាតាបិតាអាមេរិកាំងខ្មៅ នៅ TRC 5:30 ល្ងាច | 9 ប្រជុំ EONA នៅវិទ្យាល័យ Browning ម៉ោង 5:30 ល្ងាច | 10 ប្រជុំក្រុមប្រឹក្សាភិបាលអប់រំ ម៉ោង 5 ល្ងាច | 11 សិក្ខាសាលា Parent University នៅវិទ្យាល័យ Browning ម៉ោង 5:30 ល្ងាច | 12 | 13 កម្មវិធី Sankofa ថ្ងៃសៅរ៍ |
| 14 | 15 | 16 | 17 ប្រជុំក្រុមប្រឹក្សាភិបាលអប់រំ ម៉ោង 5 ល្ងាច | 18 ប្រជុំ DCAC នៅវិទ្យាល័យ Browning 5:30-6:30 ល្ងាច | 19 C.A.F.E. នៅវិទ្យាល័យ Browning ម៉ោង 9:30 ព្រឹក | 20 |
| 21 | 22 | 23 | 24 | 25 | 26 | 27 |
| 28 | | | | | | |
| | | | | | | |

WINTER BREAK

Parent University




C.A.F.E.




DCAC




EONA




DELAC

